# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី ៧

LECTURE 7

## តួអង្គចូលរួមបង្កើតនីតិអន្តរជាតិ

BODY OF WHICH ESTABLISH INTERNATIONAL LAW

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្តីផ្តើម
- ផ្នែកទី២ តួអង្គនៃនីតិអន្តរជាតិ
  - សញ្ញាណទូទៅ
- ផ្នែកទី៣ រដ្ឋ
  - សញ្ញាណទូទៅ
  - ធាតុផ្សំនៃរដ្ឋ
  - ទម្រង់នៃរដ្ឋ
- ផ្នែកទី៤ អង្គការអន្តរជាតិ
  - សញ្ញាណទូទៅ
  - ទម្រង់នៃអង្គការអន្តរជាតិ
  - លក្ខខណ្ឌគតិយុត្ត

# កម្មវត្ថុនៃមេរៀន

មេរៀនស្តីពីតួអង្គចូលរួមបង្កើតនីតិអន្តរជាតិមានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពី៖

- មានតួអង្គអ្វីខ្លះចូលរួមបង្កើតនីតិអន្តរជាតិ?
- តើតួអង្គនីមួយៗត្រូវមានធាតុផ្សំអ្វី?
- ប្រភេទផ្សេងៗនៃរដ្ឋ និងប្រភេទផ្សេងៗអង្គការអន្តរជាតិ
- សារៈសំខាន់របស់តួអង្គទាំងនេះក្នុងបង្កើតនីតិអន្តរជាតិ។

# ផ្នែកទី១ សេចក្តីផ្តើម

តួអង្គនៃនីតិអន្តរជាតិ គឺជាតួអង្គដែលដើរតួនាទីយ៉ាងសំខាន់ដើម្បីឲ្យវិធាននៃនីតិអន្តរជាតិមានរបៀបរាបរយ មានសណ្តាប់ធ្នាប់ល្អ និងបានធានដល់ការអនុវត្តនូវបទដ្ឋានអន្តរជាតិដែលតួអង្គទាំងនោះបានបង្កើតឡើង (តួអង្គជាអ្នកបង្កើតច្បាប់ និងជាអ្នកអនុវត្តច្បាប់ដែលខ្លួនបង្កើត។

# ផ្នែកទី១ សេចក្តីផ្តើម

នីតិអន្តរជាតិនឹងពិតជាគ្មានតម្លៃ ប្រសិនបើគ្មានការចូលរួមពីសំណាក់តួអង្គរបស់វានោះទេ។ តួអង្គនៃនីតិអន្តរជាតិ គឺជាបណ្តុំនៃស្ថាប័នចំនួនពីរដែលមានបុគ្គលភាពគតិយុត្ត ហើយដែលមានសិទ្ធិ អំណាចពេញលេញ និងកាតព្វកិច្ចក្នុងការចូលរួមបង្កើតនូវបទដ្ឋានគតិយុត្តអន្តរជាតិ។

# ផ្នែកទី១ សេចក្តីផ្តើម

ហើយដែល នីតិបុគ្គលភាពគតិយុត្តរបស់តួអង្គទាំងពីរនេះត្រូវបានទទួលស្គាល់ដោយនីតិអន្តរជាតិ។ សូមចាំថាសិទ្ធិអំណាច និងកាតព្វកិច្ចរបស់តួអង្គទាំងពីរនេះត្រូវអនុវត្តដោយឈរលើគោលការណ៍ច្បាប់អន្តរជាតិ។

# ផ្នែកទី២ តួអង្គនៃនីតិអន្តរជាតិ

- សញ្ញាណទូទៅ

តួអង្គនៃនីតិអន្តរជាតិ ដែលមានចំនួនពីរនោះរួមមាន រដ្ឋ និង អង្គការអន្តរជាតិ។ ចំពោះបុគ្គលឯកជន ដែលក្នុងនោះរួមមានរូបវនេនតបុគ្គល និងនីតិបុគ្គល មិនត្រូវបានរាប់បញ្ចូលថាជាតួអង្គនៃនីតិអន្តរជាតិឡើយ។

# ផ្នែកទី២ តួអង្គនៃនីតិអន្តរជាតិ

- សញ្ញាណទូទៅ

សូមបញ្ជាក់ផងដែរថាក្នុងចំណោមតួអង្គទាំងពីរនេះ គឺមានតែរដ្ឋទេដែលជាតួអង្គដែលជារដ្ឋទេដែលមានអធិបតេយ្យ។ ក្នុងចំណោមតួអង្គនៃនីតិអន្តរជាតិទាំងពីរ រដ្ឋត្រូវបានគេចាត់ថាជាតួអង្គដើមខ្សែ (តួអង្គចម្បង) ចំណែកឯអង្គការអន្តរជាតិ គឺជាតួអង្គបន្ទាប់បន្សំតែប៉ុណ្ណោះ។

# ផ្នែកទី២ តួអង្គនៃនីតិអន្តរជាតិ

តើមានមូលហេតុអ្វី ដែលគេចាត់ទុកថារដ្ឋគឺជាតួអង្គដើមខ្សែ ហើយអង្គការអន្តរជាតិ គឺជាតួអង្គបន្ទាប់បន្សំ?

តើមានមូលហេតុអ្វីដែលគេចាត់ទុកថា មានតែរដ្ឋទេជាតួអង្គដើមខ្សែ?

# ផ្នែកទី២ តួអង្គនៃនីតិអន្តរជាតិ

- សញ្ញាណទូទៅ

បានជាគេអះអាងថា មានតែរដ្ឋទេដែលជាតួអង្គដើមខ្សែនោះក៏ដោយសារតែ មានតែរដ្ឋទេជាតួអង្គដែលមានអធិបតេយ្យ ចំណែកឯអង្គការអន្តរជាតិវិញ មិនមែនជាតួអង្គដែលមានអធិបតេយ្យនោះទេ។

# ផ្នែកទី២ តួអង្គនៃនីតិអន្តរជាតិ

• សញ្ញាណទូទៅ

តើអ្នកសិក្សា ដឹងទេថាហេតុអ្វីបានជាអង្គការអន្តរជាតិគឺជាតួអង្គបន្ទាប់បន្សំ ឬ ក៏ជាតួអង្គដែលគ្មានអធិបតេយ្យ?

បានជាគេហ៊ានអះអាងថា អង្គការអន្តរជាតិគឺជាតួអង្គដែលគ្មានអធិបតេយ្យ ដោយសារតែអង្គការអន្តរជាតិត្រូវបានបង្កើតឡើងដោយរដ្ឋ។

# ផ្នែកទី២ តួអង្គនៃនីតិអន្តរជាតិ

- សញ្ញាណទូទៅ

មួយវិញទៀត សេចក្តីសម្រេចរបស់អង្គការអន្តរជាតិទាំងឡាយនោះ មិនត្រូវបានសម្រេចដោយខ្លួនឯងនោះឡើយ។ ជាទូទៅការសម្រេចចិត្តរបស់អង្គការអន្តរជាតិ មិនកើតចេញឆន្ទៈរបស់រដ្ឋដែលជាសមាជិករបស់ខ្លួន។

# ផ្នែកទី៣ រដ្ឋ

- សញ្ញាណទូទៅ

ដូចអ្នកសិក្សាបានដឹងហើយថា រដ្ឋគឺជាតួអង្គដើមខ្សែ (តួអង្គចម្បង)។ នៅសតវត្សទី១៦ រដ្ឋទំនើបត្រូវបានបង្កើតឡើង រីឯអង្គការអន្តរជាតិ ទើបតែត្រូវបានបង្កើតឡើងនៅសតវត្សទី១៩។ ហើយក៏ជាតួអង្គតែមួយគត់ដែលជានីតិបុគ្គល និងមានអធិបតេយ្យ។

# ផ្នែកទី៣ រដ្ឋ

- សញ្ញាណទូទៅ

រដ្ឋជាតួអង្គដែលមាននីតិបុគ្គលភាពអំណាចផ្ទៃក្នុង និងមាននីតិបុគ្គលភាពអំណាចអន្តរជាតិ។ នីតិបុគ្គលភាពទាំងពីរដែលរដ្ឋមាននេះហើយ គឺជាអាវុធដ៏សំខាន់ដែលមានអាចខ្វះបានក្នុងដើរតួនាទីជាតួអង្គនៃសង្គមអន្តរជាតិ។

# ផ្នែកទី៣ រដ្ឋ

- សញ្ញាណទូទៅ

តាមទស្សនៈរបស់អ្នកសិក្សាមួយចំនួនបានលើកឡើងថា រដ្ឋគឺជាមជ្ឈមណ្ឌលកណ្ដាល នៃការប្រមូលផ្ដុំនូវអំណាចផ្នែកនយោបាយ ក្នុងការដាក់ចេញនូវបទបញ្ញារ និងអនុវត្តច្បាប់ទៅលើប្រជាជនដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន។

# ផ្នែកទី៣ រដ្ឋ

- ធាតុផ្សំនៃរដ្ឋ

ដូចដែលយើងបានដឹងហើយថា គ្រប់តួអង្គទាំងឡាយត្រូវបានបង្កើតឡើងដោយមានធាតុផ្សំជាក់លាក់របស់វា។ រដ្ឋក៏ដូចជាតួអង្គផ្សេងទៀតដែល ត្រូវបានកើតឡើយដោយមានធាតុផ្សំរបស់វាជាត់លាក់ផងដែរ។

# ផ្នែកទី៣ រដ្ឋ

- ធាតុផ្សំនៃរដ្ឋ

នៅក្នុងក្របខណ្ឌនៃច្បាប់អន្តរជាតិ រដ្ឋត្រូវកើតចេញពីធាតុផ្សំចំនួនបីដែលមិនអាចខ្វះបាន។ ធាតុផ្សំទាំងបីនៃរដ្ឋរួមមានដូចជា រដ្ឋាភិបាល (អ្នកដឹកនាំ ឬ អំណាចគ្រប់គ្រង) ប្រជាជន និងទឹកដី (ដែនដី)។

# ផ្នែកទី៣ រដ្ឋ

• ធាតុផ្សំនៃរដ្ឋ

រដ្ឋនីមួយៗ ត្រូវគោរពនូវធាតុផ្សំដែលជាលក្ខខណ្ឌទាំងនេះជាចាំបាច់ គឺថារដ្ឋត្រូវមានប្រជាជនរបស់ខ្លួនក្នុងចំនួនណាមួយជាក់លាក់។ រដ្ឋត្រូវមាន រដ្ឋាភិបាលដែលជាកន្លែងប្រមូលផ្តុំនូវអំណាចនយោបាយ និងជាចុងក្រោយរដ្ឋត្រូវមានដែនដី (ទឹកដី) របស់ខ្លួនកំណត់ច្បាស់លាស់។

# ផ្នែកទី៣ រដ្ឋ

- ធាតុផ្សំនៃរដ្ឋ

ដើម្បីអាចឲ្យរដ្ឋមួយមានអត្ថិភាពទៅបាន លុះណាតែរដ្ឋទាំងនោះមានជាដាច់ខាតនូវធាតុផ្សំទាំងពីនេះ និងជាពិសេសទៅទៀតត្រូវរួមផ្សំជាមួយនិងអធិបតេយ្យ។ យើងនឹងធ្វើការសិក្សាយ៉ាងលំអិតពីធាតុផ្សំទាំងបីរបស់រដ្ឋ នៅមេរៀនទី៨ ស្តីពីរដ្ឋ (ធាតុផ្សំនៃរដ្ឋ)។

# ផ្នែកទី៣ រដ្ឋ

- ទម្រង់នៃរដ្ឋ

តាំងពីនៅក្នុងសង្គមបុរាណ និងរហូតមកដល់សង្គមទំនើប រដ្ឋអាចកើតឡើងក្នុងទម្រង់ច្រើនយ៉ាង ដូចជារបបនយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គម និងប្រព័ន្ធនៃការអប់រំផ្សេងៗ ជាអាទិ៍ ដោយស្របទៅតាមការចង់បាន និងស្ថានភាពផ្ទាល់ខ្លួនរបស់រដ្ឋទាំងនោះ។

# ផ្នែកទី៣ រដ្ឋ

- ទម្រង់នៃរដ្ឋ

កាលពីបុរាណសម័យ ការចាប់យកដែនដីណាមួយដែលគ្មានដើម្បីបង្កើតជារដ្ឋ ប៉ុន្តែនៅក្នុងសម័យកាលបច្ចុប្បន្ននេះពុំមានដែនដីដែលនៅទំនេរ ដែលអាចឲ្យគេបង្កើតរដ្ឋដូចកាលបុរាណសម័យទៀតឡើយ។ យើងសង្កេតឃើញថាទម្រង់នៃរដ្ឋបច្ចុប្បន្នមានពីរគឺ រដ្ឋទោល និងរដ្ឋសហព័ន្ធ។

# ផ្នែកទី៣ រដ្ឋ

- ទម្រង់នៃរដ្ឋ

រដ្ឋទោលៈ គឺជាទម្រង់មួយនៃរដ្ឋដែលប្រមូលផ្តុំនូវអំណាចគ្រប់គ្រងតែនៅក្នុងដៃនៃស្ថាប័នរដ្ឋបាលកណ្តាលតែមួយគត់ ហើយស្ថាប័នរដរដ្ឋបាលកណ្តាលនេះ រៀបចំធ្វើការបែងចែកនូវអំណាចទៅឲ្យស្ថាប័នថ្នាក់ក្រោម (ក្រសួង ឬ/និងថ្នាក់ខេត្ត) ទៅតាមចំណែកអំណាចដែលខ្លួនបានផ្តល់។

# ផ្នែកទី៣ រដ្ឋ

- ទម្រង់នៃរដ្ឋ

រដ្ឋទោល: ឧទាហរណ៍នៃរដ្ឋទោលមានដូចជា ព្រះរាជាណាចក្រកម្ពុជា ព្រះរាជាណាចក្រថៃ វៀតណាម ឡាវ អ៊ុយក្រែន ចិន កូរ៉េ បារាំង ជប៉ុន សឹង្ហបុរី អ៊ីតាលី សាធារណៈរដ្ឋអាហ្វ្រិកកណ្តាល កូឡុំបៀ ជាអាទ៏។

# ផ្នែកទី៣ រដ្ឋ

- ទម្រង់នៃរដ្ឋ

រដ្ឋសហព័ន្ធ៖ គឺជាទម្រង់មួយនៃរដ្ឋដែលមានការរួមបញ្ចូលគ្នានូវរដ្ឋច្រើន ដែលអំណាចនយោបាយ អំណាចយោធា និងសិទ្ធិក្នុងធ្វើទំនាក់ទំនងអន្តរជាតិ ត្រូវប្រមូលផ្តុំទៅឲ្យរដ្ឋបាលសហព័ន្ធ។ ចំណែកឯរដ្ឋដែលជាសមាជិកនៃរដ្ឋសហព័ន្ធ មានអំណាចផ្ទៃក្នុងផ្ទាល់ខ្លួនរៀងៗខ្លួន។

# ផ្នែកទី៣ រដ្ឋ

- ទម្រង់នៃរដ្ឋ

រដ្ឋសហព័ន្ធ: ឧទាហរណ៍នៃរដ្ឋសហព័ន្ធរួមមានដូចខាងក្រោម សហរដ្ឋអាមេរិក អូស្ត្រាលី ម៉ាឡេស៊ី កាណាដា អាឡឺម៉ង់ ឥណ្ឌា រ៉ុស្ស៊ី អ៊ីរ៉ាក់ អូទ្រីស បែលហ្ស៊ិក ជាអាទ៍ៗ

# ផ្នែកទី៤ អង្គការអន្តរជាតិ

- សញ្ញាណទូទៅ

អង្គការអន្តរជាតិ គឺជាតួអង្គនៃនីតិអន្តរជាតិដូចទៅនឹងរដ្ឋដែរ ហើយប្រសិនជាយើងធ្វើការប្រៀបធៀបជាមួយនិងរដ្ឋ អង្គការអន្តរជាតិ គឺគ្រាន់តែជាតួអង្គបន្ទាប់បន្សំ ឬ គេអាចហៅបានថា គឺជាតួអង្គក្លាយតែប៉ុណ្ណោះ។

# ផ្នែកទី៤ អង្គការអន្តរជាតិ

- សញ្ញាណទូទៅ

អង្គការអន្តរជាតិ គឺជាការប្រមូលផ្តុំនៃរដ្ឋដែលមានឆន្ទៈដូចគ្នា ដែលការបង្ហាញឆន្ទៈនេះ ជាការសំដែងឆន្ទៈរួម និងមិនសំដៅផលប្រយោជន៍នៃរដ្ឋណាមួយឡើយ តែជាការសំដែងដើម្បីបម្រើផលប្រយោជន៍រួម របស់រដ្ឋដែលជាសមាជិកទាំងអស់។

# ផ្នែកទី៤ អង្គការអន្តរជាតិ

- សញ្ញាណទូទៅ

អង្គការអន្តរជាតិ ត្រូវបានចាប់បដិសន្ធិដំបូងគេនៅសតវត្សទី ១៩ ដែលអង្គការអន្តរជាតិនាំពេលនោះ គឺជាអង្គការដែលមានចរិកលក្ខណៈជាស្ថាប័នបច្ចេកទេស ឧទាហរណ៍ដូចជាសហភាពទូរគមនាគមន៍អន្តរជាតិ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៨៦៥ ជាអាទ៍។

# ផ្នែកទី៤ អង្គការអន្តរជាតិ

- សញ្ញាណទូទៅ

អង្គការអន្តរជាតិដំបូងគេ ដែលមានលក្ខណៈជាសកលនោះ គឺសង្គមប្រជាជាតិ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩១៩ ដែលមានទិសដៅសំខាន់ នៅក្នុងការថែរក្សាសន្តិភាពនៅលើសាកលលោកយើងនេះ។ អង្គការនេះ ត្រូវបានជំនួសដោយអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ១៩៤៥។

# ផ្នែកទី៤ អង្គការអន្តរជាតិ

- ទម្រង់នៃអង្គការអន្តរជាតិ

អង្គការអន្តរជាតិ អាចត្រូវបានបង្កើតឡើងនៅក្នុងទម្រង់ និងជំនាញផ្សេងៗគ្នា។ អង្គការអន្តរជាតិមួយចំនួនមានលក្ខណៈជាអង្គការសាកល ហើយអង្គការអន្តរជាតិមួយចំនួនទៀតមានលក្ខណៈជាអង្គការតំបន់ ឧទាហរណ៍ EU និង UN។

# ផ្នែកទី៤ អង្គការអន្តរជាតិ

- ទម្រង់នៃអង្គការអន្តរជាតិ

អង្គការអន្តរជាតិ អាចត្រូវបានគេធ្វើការបែងចែកទៅតាមដែនសមត្ថកិច្ចរបស់វានីមួយ័ៗ គឺអង្គការនីមួយៗមានសមត្ថកិច្ចទៅតាមវិស័យ ដូចជាវិស័យសេដ្ឋកិច្ច បច្ចេកទេស ឬអាចនឹងទាក់ទងទៅនិងវិស័យបច្ចេកទេស បច្ចេកវិទ្យា និងនយោបាយផងដែរ មានដូចជា WTO ITU UN ជាអាទ៏។

# ផ្នែកទី៤ អង្គការអន្តរជាតិ

- លក្ខខណ្ឌគតិយុត្ត

អង្គការអន្តរជាតិ អាចត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញា (TREATY) ឬ ត្រូវបានបង្កើតឡើងដោយធម្មនុញ្ញា (CHARTER) ដែលគេតែងតែហៅថា សន្ធិសញ្ញាបដិដ្ឋានប័ន (សន្ធិសញ្ញាបង្កើតស្ថាប័ន) ឧទាហរណ៍ អង្គការសហប្រជាជាតិត្រូវបានបង្កើតឡើយដោយ ធម្មនុញ្ញាឆ្នាំ១៩៤៥ ជាអាទ៍។

# ផ្នែកទី៤ អង្គការអន្តរជាតិ

- លក្ខខណ្ឌគតិយុត្ត

លក្ខខណ្ឌគតិយុត្តរបស់អង្គការអន្តរជាតិ គឺត្រូវកំណត់ដោយច្បាប់ដែលបង្កើតវា ដែលកើតពីការព្រមព្រៀងនៃរដ្ឋដែលចូលរួមក្នុងការបង្កើតវានោះ ដោយមិនបម្រើផលប្រយោជន៍តែរដ្ឋដែលសមាជិកណាមួយទេ តែដើម្បីផលប្រយោជន៍រួមរបស់សមាជិកទាំងអស់ ឬ សាកលលោកទាំងមូល។

មេរៀនទី៧ ស្ដីពីតួអង្គចូលរួមបង្កើតនីតិអន្តរជាតិ ត្រូវបានបញ្ចប់។ សូមអរគុណ សម្រាប់ការតាមដានដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។